ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតដែលបានព្យួរកិច្ចសន្យាការងារក្នុងខែសីហា ខែកញ្ញា និងខែតុលា ឆ្នាំ២០២៣ នៃរោងចក្រ ទាំង៥០ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង៥០ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣០ខែវិច្ឆិកា ឆ្នាំ២០២៣**
**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**
**ចំនួន ៥០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 50 |
| 1 | ក្រុមហ៊ុន ហ៊ៀវដុង (ខេមបូឌា) លីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន នីវ ហ្គេង ឌី (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អ៊ិនហ្វុង (ខេមបូឌា) ហ្គាមិនត៍ | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហុង ជា (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន មីឈី (ខេមបូឌា) ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ឈុនឌីង ព្រីនធីង ខូអិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អេចខេ ប៊ុលតិច មេនូហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ស៊ីកូ(ភ្នំពេញ)ខូអិលធីឌី | ភ្នំពេញ |
| 9 | ក្រុមហ៊ុន ស្កាយវើតហ្វេសសិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 10 | ក្រុមហ៊ុន ញូអេសថ៍ ហ្គាម៉ិន (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 11 | ក្រុមហ៊ុន ប្រូដឡែនខេមបូឌាហ្គាមែនអ៊ិនឌិសស្ទ្រី | ភ្នំពេញ |
| 12 | ក្រុមហ៊ុន ជេ-គូរី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុន ខេវីធី អ៊ីអឹមប៊ី បេស (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 14 | ក្រុមហ៊ុន ខូបេស (ខេមបូឌា) ហ្វ៊ីស ហ្គាម៉ិន ឯ.ក | ភ្នំពេញ |
| 15 | ក្រុមហ៊ុន ស៊ូស៊ូ (ខេមបូឌា) អ៊ិនធើណេសិនណល ឯ.ក | ភ្នំពេញ |
| 16 | ក្រុមហ៊ុន សានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 17 | ក្រុមហ៊ុន អេ ផ្លាស់ អេ ស៊ូ ( ខេមបូឌា ) ខូអិលធីឌី | ភ្នំពេញ |
| 18 | ក្រុមហ៊ុន ទ្រីលាន ហ្គាសមេន (ខេមបូឌា) ឯ. ក | ភ្នំពេញ |
| 19 | ក្រុមហ៊ុន វីកម៉ាក ហ្វេសិន (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 20 | ក្រុមហ៊ុន ហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 21 | ក្រុមហ៊ុន អេ ខេ អិម ហ្គាមេន | ភ្នំពេញ |
| 22 | ក្រុមហ៊ុន ម៉ាស្ទ័រ&ហ្វ្រែង(ខេមបូឌា)ខូអិលធីឌី | កណ្ដាល |
| 23 | ក្រុមហ៊ុន ហ្វ្រេត បេសវ៉េ មេនញូហ្វេកឈើរីង ឯ.ក | កណ្ដាល |

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| 24 | ក្រុមហ៊ុន ហ្គែននី វីន ប៉ែក (ខេមបូឌា) ឯ.ក | កណ្ដាល |
| 25 | ក្រុមហ៊ុន ជី សូល ហ្គៀ (ខេមបូឌា) ឯ.ក | កណ្ដាល |
| 26 | ក្រុមហ៊ុន ណាហ្គាភីស ខបភើរេសិន លីមីធីត_1 | កណ្ដាល |
| 27 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្ដាល |
| 28 | ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន | កំពង់ស្ពឺ |
| 29 | ក្រុមហ៊ុន ថ្លាញតិច (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 30 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 31 | ក្រុមហ៊ុន វីង ស្តារ ស៊ូ | កំពង់ស្ពឺ |
| 32 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូត វែរ ឯ.ក | កំពង់ស្ពឺ |
| 33 | ក្រុមហ៊ុន វ៉េត ម៉ាស ហ្គាម៉ិន (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 34 | ក្រុមហ៊ុន ស្មាតស៊ើតស៏ ហ្គាមេន មេនូហ្វេកធើរីង (ខេមបូឌា) | កំពង់ស្ពឺ |
| 35 | ក្រុមហ៊ុន ធិច សេល (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 36 | ក្រុមហ៊ុន អេតា អឺភែរឺល ឯ.ក | តាកែវ |
| 37 | ក្រុមហ៊ុន ប្រាយនេស(ខេមបូឌា)ហ្គាម៉ិន ហ្វេកធើរី ឯក | តាកែវ |
| 38 | ក្រុមហ៊ុន ប្រាយ ហ្គ្លាស់ស៊ីង ឯ.ក | តាកែវ |
| 39 | ក្រុមហ៊ុន អៅដរ ហ្គៀ (ខេមបូឌា) ឯ.ក | តាកែវ |
| 40 | ក្រុមហ៊ុន ឡាយហ្វេងអៅដរ(ខេមបូឌា)ឯ.ក (១) | តាកែវ |
| 41 | ក្រុមហ៊ុន អេចស៊ី គ្លូប៊ល ថេកស្តាយ ឯ.ក | តាកែវ |
| 42 | ក្រុមហ៊ុន មេតថេក (ខេបូឌា) ខប លីមីធីត | កំពង់ចាម |
| 43 | ក្រុមហ៊ុន ស៊ីភីស៊ីជី អ៊ិនធើណេសិនណល | កំពង់ចាម |
| 44 | ក្រុមហ៊ុន ហឺវ៉ាយហ្សិន  អៅដរ(ខេមបូឌា)ខូ,.អិលធីឌី_1 | កំពង់ឆ្នាំង |
| 45 | ក្រុមហ៊ុន អ៊ឹម និង វ៉េ កាត់ដេរអន្តរជាតិ អិលធីឌី. | កំពង់ឆ្នាំង |
| 46 | ក្រុមហ៊ុន តៃអ៊ីហ្សី អ៊ិនធីណាស្សិនណលខូ.,អិលធីឌី | ពោធិ៍សាត់ |
| 47 | ក្រុមហ៊ុន ស៊ីកូ (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 48 | ក្រុមហ៊ុន វីប៊ីការ ហ៊ែរ ប្រដាក់ (ខេមបូឌា) | ព្រះសីហនុ |
| 49 | ក្រុមហ៊ុន ខេមបូឌាន ស្តេវ៉ាយដ៍ ស្ព័ត ឯ.ក | ព្រះសីហនុ |
| 50 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |